ISSN 1560-7615 / ISBN 978-99950-52-06-5

ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៥ លេខ ៣ | កក្កដា - កញ្ញា ឆ្នាំ២០១១ | តម្លៃ ១.៥០០៛

# ការដោះស្រាយបញ្ហាចំណាកស្រុកមិនស្របច្បាប់នៅកម្ពុជា[១]

## សេចក្ដីផ្ដើម

នៅប្រទេសកម្ពុជា ចំណាកស្រុកភាគច្រើនមានលក្ខណៈមិនស្របច្បាប់ ហើយតាមធម្មតា ការធ្វើដំណើរ តែងមានអ្នកធ្លាប់ធ្វើចំណាកស្រុកពីមុន ឬមេខ្យល់ជួយសម្របសម្រួល។ បញ្ហានេះ បានប្រែជាស្មុគស្មាញ និងពិបាកគ្រប់គ្រងខ្លាំងណាស់ ហើយប៉ះពាល់ដល់ អភិបាលកិច្ចចំណាកស្រុកនៃកម្លាំងពលកម្ម។ វាចោទបញ្ហាខាងការគ្រប់គ្រង ពីព្រោះការធ្វើដំណើរតែងកើត ឡើងនៅក្រៅក្របខ័ណ្ឌច្បាប់នៃប្រទេសបញ្ជូន និងប្រទេសទទួលពលករ ដែលនាំឲ្យលំបាកដល់ការកត់ត្រា និងតាមដាន ហើយក៏បង្កជាបញ្ហាដល់ការការពារផងដែរ។ ស្ថានភាពមិនស្របច្បាប់នេះ ធ្វើឲ្យជនចំណាកស្រុកងាយរងគ្រោះបំផុត ដោយការរំលោភ និងការកេងប្រវ័ញ្ចពីសំណាក់និយោជក ហើយជារឿយៗ មិនបានទទួលការការពារផ្នែកច្បាប់ទេ។ ក្នុងករណីធ្ងន់ធ្ងរបំផុត ពួកគេត្រូវរងគ្រោះដោយការជួញដូរមនុស្ស។ គម្លាតធ្ងន់ធ្ងររវាងគោលនយោបាយ និងការអនុវត្តជាក់ស្ដែងទាក់ទងនឹងចំណាកស្រុកមិនស្របច្បាប់ បង្ហាញពីតម្រូវការកាន់តែខ្លាំងនូវការវិភាគស៊ីជម្រៅ និងអន្តរាគមន៍គោលនយោបាយ ដែលជាកម្មវត្ថុដ៏ចម្បងនៃការសិក្សាស្រាវជ្រាវនេះ។



ការងារនៅលើទូកនេសាទសមុទ្រ មានគ្រោះថ្នាក់ និងមានការរំលោភបំពានខ្លាំងបំផុត សម្រាប់ជនចំណាកស្រុកជាបុរស។

## ការពិនិត្យត្រួសៗពីចំណាកស្រុកមិនស្របច្បាប់នៅកម្ពុជា

### និយមន័យ និងស្ថានភាព

ចំណាកស្រុកមិនស្របច្បាប់ គេតែងកំណត់ជាទូទៅថាជាការធ្វើដំណើរមិនស្របច្បាប់ទៅធ្វើការនៅក្នុងប្រទេសណាមួយ ឬការធ្វើដំណើរដោយមិនមានការអនុញ្ញាតឲ្យធ្វើការ និងមានរួមបញ្ចូលផងដែរនូវ ករណីអ្នកធ្វើចំណាកស្រុកស្របច្បាប់ ប៉ុន្តែក្រោយមកបានបាត់បង់ស្ថានភាពស្របច្បាប់របស់ខ្លួន (ឧទាហរណ៍ ដោយសារការស្នាក់នៅហួសពេលកំណត់) (UN General Assembly; Brennan 1984; Global Commission on International Migration 2005; LeVoy & Geddie2010; Lee 2005)។ ពាក្យ "មិនស្របច្បាប់" អាចជំនួសបានដោយពាក្យ "គ្មានឯកសារត្រឹមត្រូវ" "គ្មានការអនុញ្ញាត" "មិនផ្លូវការ" ឬ "លួចលាក់"។

ចំណាកស្រុកមិនស្របច្បាប់ ជាទម្រង់ពេញនិយមបំផុតសម្រាប់ការធ្វើដំណើរឆ្លងកាត់ព្រំដែន ក្នុងចំណោមពលករកម្ពុជាដែលស្វែងរកការងារធ្វើនៅក្រៅប្រទេស។ ចំណាកស្រុកមិនស្របច្បាប់មានពីរប្រភេទ។ **ប្រភេទទី១** គឺចំណាកស្រុកចម្ងាយជិតនៅតាមព្រំដែនកម្ពុជា-ថៃ។ នៅទីនោះ ការងារភាគច្រើនជាប្រភេទកសិកម្ម ដែលជនចំណាកស្រុកដឹងពី សាច់ញាតិ មិត្តភក្តិ ឬអ្នកភូមិ ដែលបានធ្វើចំណាកស្រុកពីមុន។ អ្នកធ្លាប់ត្រួសត្រាយផ្លូវទាំងនេះ អាចជួយសម្រួលដល់ការរកកន្លែងធ្វើការ

## មាតិកា

ការដោះស្រាយចំណាកស្រុកមិនស្របច្បាប់នៅកម្ពុជា............. ១
ការពិចារណាពីផលប៉ះពាល់នៃចំណាកស្រុកលើឪពុកម្ដាយវ័យជរា៖ ភស្តុតាងពីឃុំពីរ ក្នុងខេត្តបាត់ដំបង.................. ៧
ការពង្រឹងផលចំណេញ ការត្រៀមរៀបចំសម្រាប់ការផ្លាស់ប្ដូរ៖ កម្លាំងពលកម្ម និងពិពិធកម្មនៅកម្ពុជា......................... ១២
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ....................... ១៥
— ស្ថានភាពក្នុងប្រទេស........................ ១៧
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........................................ ២៤

១ លោក ហ៊ីង-វុត្ថា និង លោក លន់-ពិដេ ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

**តារាង ១៖ ជនចំណាកស្រុកមិនស្របច្បាប់នៅថៃ បែងចែកតាមវិស័យសេដ្ឋកិច្ចឆ្នាំ២០០៩**

| វិស័យសេដ្ឋកិច្ច | ចំនួនកម្មករ | | | |
|---|---|---|---|---|
| | កម្ពុជា | ឡាវ | ភូមា | សរុប |
| នេសាទ | 14969 | 1800 | 39809 | 56578 |
| ទាក់ទិននឹងនេសាទ | 6020 | 1180 | 129773 | 136973 |
| កសិកម្ម និងចិញ្ចឹមសត្វ | 24085 | 18035 | 179583 | 221703 |
| ពាក់ព័ន្ធនឹងកសិកម្ម និងចិញ្ចឹមសត្វ | 7077 | 4469 | 62611 | 74157 |
| សំណង់ | 32465 | 12635 | 175136 | 220236 |
| យករ៉ែ/ថ្ម | 61 | 35 | 1747 | 1843 |
| លក់ដុំ &លក់រាយ | 4778 | 7565 | 30471 | 42814 |
| អាហារ និងភេសជ្ជៈ (អ្នកលក់) | 4483 | 13074 | 36668 | 54225 |
| បម្រើការតាមផ្ទះ | 6578 | 21267 | 101945 | 129790 |
| ផ្សេងៗ | 24245 | 30794 | 321024 | 376063 |
| សរុប | 124761 | 110854 | 1078767 | 1314382 |

*ប្រភព៖ Paitoonpong & Sukaruji (ជិតចេញផ្សាយ)*

និងបង្កើតជាបណ្តាញតភ្ជាប់រវាងក្រុមគ្រួសារនៅជនបទ និងតំបន់គោលដៅនៅថៃ។ របៀបរបបអនុវត្តនេះ ជនចំណាកស្រុកបានចាត់ទុកជាទូទៅថា មានសុវត្ថិភាព ងាយស្រួល និងអស់ចំណាយតិចសមរម្យ និងមិនចាំបាច់ត្រូវចំណាយពេលរង់ចាំ មិនត្រូវការឯកសារ និងនីតិវិធីជ្រើសរើសស្មុគស្មាញទេ។ សម្រាប់អ្នកដែលទិញលិខិតឆ្លងកាត់ព្រំដែន សម្រាប់រយៈពេលមួយសប្តាហ៍ ហៅថា *បាត* ជាដំបូងត្រូវចំណាយប្រាក់សម្រាប់ចំណាកស្រុកនេះ ពី ៣,០ ទៅ ៥,៥ដុល្លារ ដោយក្នុងនេះ មានចំណាយលើរថយន្តឈ្នួល ពី ២,៥ ទៅ ៥,០ដុល្លារ និងលើលិខិតឆ្លងកាត់ព្រំដែន ០,៥ដុល្លារ។ ជនចំណាកស្រុក ត្រូវធ្វើលិខិតឆ្លងកាត់ព្រំដែនជាថ្មីរៀងរាល់សប្តាហ៍នៅច្រកព្រំដែន។ ពួកគាត់ក៏អាចទិញលិខិតឆ្លងកាត់ព្រំដែនរយៈពេល១ឆ្នាំ បានដែរ ដែលមានតម្លៃ ១៩ដុល្លារ។

**ចំណាកស្រុកប្រភេទទី២** គឺការធ្វើដំណើរចម្ងាយឆ្ងាយទៅថៃ ឬម៉ាឡេស៊ី ដើម្បីធ្វើការលើទូកនេសាទ ឬធ្វើជាកម្មករសំណង់ ឬកម្មកររោងចក្រ។ ក្នុងករណីភាគច្រើន ជនចំណាកស្រុកធ្វើដំណើរជាក្រុមតូចៗជាមួយមេខ្យល់ ទៅកន្លែងធ្វើការនៅថៃ។ សេវាជាមូលដ្ឋានដែលមេខ្យល់ផ្តល់ឲ្យ រួមមាន ការធ្វើដំណើរទៅព្រំដែន និងការសុំលិខិតអនុញ្ញាតឲ្យធ្វើការ និងការរកការងារនៅក្នុងប្រទេសគោលដៅ។ ជនចំណាកស្រុកត្រូវបង់ជាមុននូវប្រាក់កម្រៃសម្រួលការនេះ ដែលមានចំនួនពី ១០០ ទៅ ២០០ដុល្លារ។

ថៃ ជាទិសដៅចំបងនៃចំណាកស្រុកមិនស្របច្បាប់ពីកម្ពុជា។ អង្គការចំណាកស្រុកអន្តរជាតិ (International Organisation for Migration) បានបញ្ជាក់ថា អាចមានប្រជាជនកម្ពុជាដល់ ១៨០.០០០នាក់ ដែលធ្វើការក្រៅផ្លូវការនៅថៃ។ ក្រសួងការងារប្រទេសថៃ (Paitoonpong & Sukaruji ជិតចេញផ្សាយ) បានប៉ាន់ស្មានថា មានជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់ប្រមាណ ១២០.០០០នាក់។ យោងតាមប្រភពដដែល (តារាង១) ជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់ភាគច្រើននៅប្រទេសថៃ ធ្វើការក្នុងវិស័យកសិកម្ម (៤២%) និងសំណង់ (២៦%)។ ម៉ាឡេស៊ី ជាគោលដៅចម្បងទី២ នៃជនចំណាកស្រុកមិនស្របច្បាប់ ហើយក្រុមនេះភាគច្រើនជាជនជាតិភាគតិចចាម។ ផ្លូវធ្វើដំណើរតាមធម្មតា គឺជិះយន្តហោះទៅម៉ាឡេស៊ីជាទេសចរ បន្ទាប់មកស្វែងរកការងារដោយមិនមានលិខិតអនុញ្ញាតការងារ។ ជនចំណាកស្រុកមិនស្របច្បាប់ទៅម៉ាឡេស៊ីភាគច្រើន គឺដើម្បីស្វែងរកការងារធ្វើនៅក្នុងវិស័យសំណង់ និងកម្មន្តសាល។

## *លក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចនៃជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់*

គ្រួសារជាងពាក់កណ្តាលក្នុងគំរូតាង[២] មានសមាជិកគ្រួសារធ្វើចំណាកស្រុក ដែលភាគច្រើនមិនស្របច្បាប់។ នារីមានប្រមាណ ១/៣នៃជនចំណាកស្រុក (តារាង ២)។ ទាំងជនចំណាកស្រុកស្របច្បាប់ និងមិនស្របច្បាប់ ភាគច្រើនមានអាយុជិត៣០ឆ្នាំ។ ទំហំគ្រួសារជាមធ្យម គឺប្រមាណ ៥នាក់ ដែលប្រហាក់ប្រហែលគ្នានឹងគ្រួសារមិនធ្វើចំណាកស្រុក។ ប៉ុន្តែជនចំណាកស្រុកស្របច្បាប់ និងមិនស្របច្បាប់ មានកម្រិតអប់រំខុសគ្នាច្រើន (តារាង ៣)។

គ្រួសារដែលមានជនចំណាកស្រុកមិនស្របច្បាប់ មានស្ថានភាពសេដ្ឋកិច្ច ទាបជាងគ្រួសារដែលមានជនចំណាកស្រុកស្របច្បាប់ ឬមិនធ្វើចំណាកស្រុក។ តារាង ៤ បង្ហាញថា ជនចំណាកស្រុកមិនស្របច្បាប់ ចំណាយលើអាហារប្រមាណ ១៩% តិចជាងជនមិនធ្វើចំណាកស្រុក ប៉ុន្តែតិចជាងជនចំណាកស្រុកស្របច្បាប់បន្តិចបន្តួចប៉ុណ្ណោះ។ ភាពខុសគ្នានៃចំណាយរវាងជនចំណាកស្រុកមិនស្របច្បាប់ និងស្របច្បាប់មិនមានសារៈសំខាន់ខាងស្ថិតិទេ។ ចំណាយប្រើប្រាស់មិនមែនអាហាររបស់ជនចំណាកស្រុកមិនស្របច្បាប់ មានចំនួន ៤០%

---

២ អង្កេតនេះ វិទ្យាស្ថាន CDRI បានធ្វើឡើងនៅចុងឆ្នាំ២០០៧ សម្រាប់គម្រោងស្រាវជ្រាវ "ចំណាយ និងផលចំណេញនៃចំណាកស្រុកពលកម្មឆ្លងកាត់ព្រំដែនក្នុង GMS៖ ករណីសិក្សាពីកម្ពុជា" ។ អង្កេតនេះបានសម្ភាសន៍ ៥២៦ គ្រួសារមកពី ៦ភូមិ ដែលមានសកម្មភាពចំណាកស្រុកច្រើន។

**តារាង ២៖ គ្រួសារ និងសមាជិកធ្វើចំណាកស្រុក**

| | ស្របច្បាប់ | % | មិនស្របច្បាប់ | % | មិនធ្វើចំណាកស្រុក | % | សរុប |
|---|---|---|---|---|---|---|---|
| គ្រួសារ | 16 | 3 | 293 | 56 | 217 | 41 | 526 |
| ជនចំណាកស្រុក | 19 | 4 | 494 | 96 | - | - | 513 |
| ស្ត្រី | 6 | 3 | 171 | 97 | - | - | 177 |

*ប្រភព៖ Chan (2009)*

**តារាង៣៖ លក្ខណៈសង្គមរបស់ជនចំណាកស្រុក និងមិនមែនចំណាកស្រុក**

| ប្រភេទចំណាកស្រុក | ស្របច្បាប់ | មិនស្របច្បាប់ | មិនធ្វើចំណាកស្រុក |
|---|---|---|---|
| ទំហំគ្រួសារជាមធ្យម | 5.0 | 5.6 | 4.8 |
| ចំនួនសមាជិកក្នុងបន្ទុក* | 1.6 | 2.2 | 2.1 |
| អាយុជាមធ្យមរបស់ជនចំណាកស្រុក | 28.6 | 27.8 | - |
| ចំនួនឆ្នាំជាមធ្យមនៃការសិក្សារបស់ជនចំណាកស្រុក | 6.8 | 4.3 | - |

*សមាជិកគ្រួសារអាយុតិចជាង ១៥ឆ្នាំ ឬច្រើនជាង ៥៤ឆ្នាំ។

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធដោយផ្អែកលើទិន្នន័យអង្កេតឆ្នាំ២០០៧។*

តិចជាងជនចំណាកស្រុកស្របច្បាប់ និង ១៣% តិចជាងជនមិនធ្វើចំណាកស្រុក។ ចំណាយជាមធ្យមរបស់ជនចំណាកស្រុកមិនស្របច្បាប់ មានចំនួន ១៧% តិចជាងចំណាយរបស់ជនមិនធ្វើចំណាកស្រុក។ តម្លៃទ្រព្យសម្បត្តិរបស់គ្រួសារជនចំណាកស្រុកមិនស្របច្បាប់ មានប្រហែលពាក់កណ្តាលនៃគ្រួសារជនចំណាកស្រុកស្របច្បាប់ (ទាំងក្នុងឆ្នាំ២០០២ និង ២០០៧)។

### មូលហេតុនាំឲ្យមានចំណាកស្រុកមិនស្របច្បាប់

ចំណាកស្រុកមិនស្របច្បាប់ មានមូលហេតុចម្រុះ។ ការសិក្សានេះបានរកឃើញថា គោលនយោបាយពលកម្ម និងលក្ខខណ្ឌទីផ្សារពលកម្មក្នុងប្រទេសម្ចាស់ផ្ទះជាមូលហេតុមួយនាំឲ្យមាន លំហូរជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់ដ៏ច្រើនសន្ធឹកនេះ។ ម្យ៉ាងទៀតក៏មានភាពមិនស៊ីគ្នារវាងតម្រូវការពលកម្ម និងការផ្គត់ផ្គង់ពលកម្មក្នុងប្រទេសម្ចាស់ផ្ទះដែរ ព្រមទាំងទីផ្សារងងឹតដែលមានបណ្តាញរឹងមាំ សម្រាប់ផ្គត់ផ្គង់ពលករ។ ការអនុវត្តច្បាប់ធូររលុងប្រឆាំងនឹងនិយោជក ដែលជួលពលករមិនស្របច្បាប់ បានលើកទឹកចិត្តពួកគេឲ្យជ្រើសរើសពលករពីទីផ្សារងងឹត។ ក្នុងករណីប្រទេសថៃ អតុល្យភាពអាចមើលឃើញច្បាស់ តាមការចុះឈ្មោះពលករមិនស្របច្បាប់ចាប់ពីឆ្នាំ១៩៩២ មក (Paitoonpong & Sukaruji ជិតចេញផ្សាយ)។

**តារាង ៤៖ មធ្យម (mean) ចំណាយប្រើប្រាស់ប្រចាំថ្ងៃ និងតម្លៃទ្រព្យសម្បត្តិ (គិតក្នុងមនុស្សម្នាក់) នៃគ្រួសារគំរូតាងមួយចំនួន**

| | | មធ្យម (Mean) | | | T-Value† | | |
|---|---|---|---|---|---|---|---|
| | | ស្របច្បាប់(a) | មិនស្របច្បាប់ (b) | មិនចំណាកស្រុក (c) | (b)–(a) | (b)–(c) | (a)–(c) |
| ចំណាយប្រើប្រាស់ (រៀល/នាក់) | អាហារ | 1142.0 | 1168.6 | 1391.8 | 0.2 | -5.3*** | -2.0** |
| | | (478.5) | (450.1) | (469.4) | | | |
| | មិនមែនអាហារ | 1223.0 | 877.2 | 990.4 | -2.2** | -1.9* | 1.2 |
| | | (752.46) | (578.8) | (668.2) | | | |
| | សរុប | 2515 | 2249 | 2641 | -0.8 | -3.3*** | -0.3 |
| | | (1155) | (1241) | (1367) | | | |
| ទ្រព្យសម្បត្តិ (ពាន់រៀល/នាក់)‡ | 2002 | 818.9 | 371.2 | 433.9 | -3.3*** | -1.2 | 2.5** |
| | | (727.2) | (517.3) | (562.5) | | | |
| | 2007 | 1265.9 | 665.5 | 721.1 | -3.1*** | -0.8 | 2.8*** |
| | | (670.6) | (765.9) | (737.7) | | | |

*សម្គាល់៖ Standard deviation in parentheses. † Two-sample t-test of different means with equal variance.*

*‡ Excluding land and house. * significant at 10% level. ** significant at 5% level. *** significant at 1% level.*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើទិន្នន័យអង្កេតឆ្នាំ២០០៧។*

គិតមកដល់ឆ្នាំ២០០៩ អាជ្ញាធរថៃបានចុះឈ្មោះជនចំណាកស្រុកមិនស្របច្បាប់កម្ពុជាបាន ១២៤.៧៦១នាក់ (*ibid*)។

បញ្ហានៅស្រុកកំណើត ក៏ជម្រុញឲ្យប្រជាជនចាកចេញដែរ។ ជម្លោះផ្ទៃក្នុង និងអស្ថិរភាពនយោបាយ លែងជាបញ្ហាបារម្ភចម្បងរបស់ប្រជាជនកម្ពុជាទៀតហើយ។ ឥឡូវនេះបញ្ហាសេដ្ឋកិច្ចជាពិសេសភាពក្រីក្រ ទើបជាបញ្ហាចម្បង។ តួលេខចំណាយប្រើប្រាស់ក្នុងតារាង ៤ បង្ហាញថា ជនចំណាកស្រុកកំពុងរស់នៅក្រោមបន្ទាត់ក្រីក្របន្តិច ហើយមានច្រើននាក់ណាស់ប្រាថ្នាត្រឹមតែរំដោះខ្លួនពីភាពក្រីក្រប៉ុណ្ណោះ។ ចំណាកស្រុកក្នុងប្រទេសទៅកាន់ទីប្រជុំជន ក៏ជាជម្រើសមួយដែរ ប៉ុន្តែការងារមានតែក្នុងផ្នែកអតិពលកម្មប្រើជំនាញទាប ដូចជា ខាងសំណង់ និងកាត់ដេរជាដើម។

ហេតុអ្វីបានជាប្រជាជន មិនជ្រើសយកចំណាកស្រុកស្របច្បាប់? លក្ខណៈសេដ្ឋកិច្ច-សង្គមកិច្ចរបស់ជនចំណាកស្រុកមិនបានបង្ហាញថា ភាពខុសគ្នាក្នុងស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចបានជះឥទ្ធិពល ដល់ការសម្រេចចិត្តរបស់ពួកគេនោះទេ។ ម្យ៉ាងវិញទៀត អ្នកទាំងនោះក៏មិនមែនកើតមកសម្រាប់តែធ្វើជាពលករមិនស្របច្បាប់នោះដែរ។ ពួកគេអាចជ្រើសយកវិធីណាដែលខ្លួនអាចរកបាន និងរ៉ាប់រងចំណាយបាន។ លោក Chan (2009) បានអះអាងថា ចំណាយពីដំបូងដ៏ច្រើននៃចំណាកស្រុកស្របច្បាប់ ជាហេតុផលចម្បងមួយ នាំឲ្យពួកគេចូលចិត្តធ្វើចំណាកស្រុកមិនស្របច្បាប់ ទោះបីជាចំណាកស្រុកស្របច្បាប់វាផ្ដល់ប្រាក់ចំណេញសុទ្ធបានច្រើនជាងក្ដី។ លោក Chan វែកញែកថា ដើម្បីបានការងារស្របច្បាប់នៅប្រទេសថៃ ពលករត្រូវការប្រាក់ដល់ប្រមាណ ៧០០ដុល្លារ ដែលពលករនៅជនបទកម្ពុជាភាគច្រើន មិនអាចរកបានទេ។ បើសិនធ្វើចំណាកស្រុកមិនស្របច្បាប់វិញ ម្នាក់ៗចំណាយអស់តិចជាងនេះឆ្ងាយណាស់។ ទិន្នន័យបែបគុណវិស័យ ក៏បានបញ្ជាក់គាំទ្រដល់ការអះអាងរបស់លោក Chan ដែលថា ជនចំណាកស្រុកមិនស្របច្បាប់ដែលក្រីក្រខ្លាំង មិនឃើញមានចំណាប់អារម្មណ៍ខិតខំស្វែងរកការងារ តាមរយៈភ្នាក់ងារជ្រើសរើសពលករស្របច្បាប់នោះទេ។ ចំណាកស្រុកស្របច្បាប់ទៅប្រទេសថៃ អាចចំណាយពេលអស់ពី ៣ ទៅ ៦ខែ រីឯចំណាកស្រុកមិនស្របច្បាប់វិញ ចំណាយពេលអស់ត្រឹមតែ ២-៣ថ្ងៃ និងត្រូវការឯកសារតិចតួចជាង ឬគ្មានសោះ។

ទីតាំងភូមិសាស្ត្រនៅជិត ក៏ជាកត្តាបង្កើនលំហូរចំណាកស្រុកក្រៅផ្លូវការដែរ (Battistella 2002)។ ប្រទេសកម្ពុជាមានព្រំដែនគោកជាប់ប្រទេសថៃ ប្រវែង ៨០៣គីឡូម៉ែត្រ ដែលមានច្រកមិនផ្លូវការជាច្រើន។ ព្រំដែនដ៏វែងបែបនេះ ពិបាកគ្រប់គ្រងខ្លាំងណាស់។ ម្យ៉ាងទៀត បណ្ដាញមានស្រាប់ ក៏បានជួយសម្រួលដល់ដំណើររបស់ជនចំណាកស្រុកមិនស្របច្បាប់ ដែលតែងពឹងផ្អែកលើមិត្តភក្តិ ឬសាច់ញាតិដែលកំពុងធ្វើការនៅក្នុងប្រទេសម្ចាស់ផ្ទះដែរ។ បណ្ដាញប្រភេទនេះ បានជួយកាត់បន្ថយបន្ទុកចំណាយលើការស្វែងរកការងារ និងបង្កើនលទ្ធភាពរកបានការងារធ្វើ (Chiuri *et al.* 2005)។

## បញ្ហា និងការប្រឈមនៃចំណាកស្រុកមិនស្របច្បាប់

ពលករចំណាកស្រុកមិនស្របច្បាប់ ប្រឈមនឹងហានិភ័យកាន់តែខ្ពស់នៃការកេងប្រវ័ញ្ច និងការមិនទទួលបានសិទ្ធិជាមូលដ្ឋាន ដូចជា ការថែទាំសុខភាព និងការអប់រំជាដើម (IOM 2003)។ កន្លងមកមានភស្តុតាងជាច្រើននៃការរំលោភដោយនិយោជក ដូចជា ការបង្ខំឲ្យធ្វើការលើសម៉ោង ការកាត់ប្រាក់ខែ និងការបៀតបៀនផ្លូវភេទ បៀវត្សរ៍ទាបជាងកម្រិតមធ្យម និងលក្ខខណ្ឌការងារមិនល្អ។

Naro (2009) បានចងក្រងករណីសិក្សាអំពីជនចំណាកស្រុកកម្ពុជា ដែលបានទទួលរងការរំលោភបំពានពីនិយោជក ដូចជា ខ្លះត្រូវធ្វើការច្រើនម៉ោងតែបានប្រាក់កម្រៃទាប ហើយខ្លះទៀតបានទទួលទារុណកម្មលើរូបរាងកាយ នៅពេលពួកគេមិនព្រមធ្វើតាមបញ្ជា។ Marshall (2001) បានបង្ហាញភស្តុតាងពីកុមារកម្ពុជា ដែលគេជួញដូរឲ្យធ្វើជាអ្នកសុំទាន និងអ្នកលក់ផ្កាតាមផ្លូវ ខណៈដែលជនចំណាកស្រុកជាស្ត្រី ត្រូវគេបង្ខំឲ្យធ្វើជាអ្នកបម្រើផ្លូវភេទ។ យោងតាមរបាយការណ៍ពី UNIAP (2010) ជារៀងរាល់ឆ្នាំមានប្រជាជនកម្ពុជារាប់ពាន់នាក់ ត្រូវបានគេជួញដូរទៅប្រទេសថៃ។ បុរសៗត្រូវគេជួញដូរឲ្យទៅធ្វើការលើទូកនេសាទ ឬធ្វើជាកម្មករសំណង់។ នារីៗ ត្រូវគេជួញដូរឲ្យធ្វើការក្នុងឧស្សាហកម្មកំសាន្ត ដែលមានទាំងបនពេស្យាចារផង។

ការងារនៅលើទូកនេសាទសមុទ្រ មានគ្រោះថ្នាក់ និងមានការរំលោភបំពានខ្លាំងបំផុត សម្រាប់ជនចំណាកស្រុកជាបុរស។ ក្រៅពីការមិនបើកប្រាក់ខែឲ្យ ជនចំណាកស្រុកត្រូវទទួលរងលក្ខខណ្ឌការងារធ្ងន់ធ្ងរ ហើយត្រូវទទួលរងទារុណកម្មលើរាងកាយ ប្រសិនបើមេការរកឃើញថាមានកំហុសអ្វីមួយ។ ពួកគេត្រូវធ្វើការរហូតដល់១៥ម៉ោងក្នុងមួយថ្ងៃ និងមានករណីរាយការណ៍អំពីការបង្ខំឲ្យប្រើប្រាស់គ្រឿងញៀន ដើម្បីអាចទ្រាំទ្រនឹងការងារធ្ងន់ធ្ងរបាន (ICSW 2007)។ ជនចំណាកស្រុកមួយចំនួន ត្រូវគេជួញដូរ និងយកទៅលក់ដោយមិនដឹងខ្លួន ដូច្នេះត្រូវធ្វើការជាច្រើនឆ្នាំដើម្បីដោះបំណុល (*ibid*)។ ក្រៅពីការកេងប្រវ័ញ្ច ជនចំណាកស្រុកកម្ពុជាមិនស្របច្បាប់ជាច្រើនមិនអាចទទួលបានសេវាសង្គម ដូចជា ការថែទាំសុខភាព និងការអប់រំសម្រាប់កូនៗរបស់ពួកគេ ពីព្រោះត្រូវរត់គេចពីអាជ្ញាធរដែលជាមធ្យោបាយតែមួយគត់ ដើម្បីដោះស្រាយស្ថានភាពលួចលាក់របស់ខ្លួន។

## វិធីផ្លែកច្បាប់ដើម្បីដោះស្រាយបញ្ហាចំណាកស្រុកមិនស្របច្បាប់

មានការមូលមតិក្នុងអន្តរជាតិថា ចំណាកស្រុកមិនស្របច្បាប់គួរតែដោះស្រាយក្នុងលក្ខណៈរួម និងគ្រប់ជ្រុងជ្រោយ តាមរយៈការពិនិត្យពីមូលហេតុនានា ការដោះស្រាយផលប៉ះពាល់របស់វា និងការបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ។

### *ដោះស្រាយមូលហេតុនៃចំណាកស្រុកមិនស្របច្បាប់*

ភាពក្រីក្ររ៉ាំរ៉ៃ បន្ទុកចំណាយខ្ពស់លើចំណាកស្រុកស្របច្បាប់ និងការអនុវត្តខុសឆ្គងដោយទីភ្នាក់ងារឯកជនមួយចំនួនដែលរកការងារឲ្យធ្វើ បានជំរុញពលករកម្ពុជាឲ្យធ្វើចំណាកស្រុកតាមរយៈបណ្ដាញក្រៅផ្លូវការ។ អន្តរាគមន៍ផ្សេងៗដើម្បីដោះស្រាយកត្តាជំរុញទាំងនេះ នឹងជួយកាត់បន្ថយចំណាកស្រុកមិនស្របច្បាប់។

*ពង្រឹងការអភិវឌ្ឍសហគមន៍ដើម៖* ការវិភាគខាងលើបង្ហាញថា គ្រួសារនានាជ្រើសយកចំណាកស្រុកដើម្បីគេចផុតពី

ភាពក្រីក្រធ្ងន់ធ្ងរ និងការលំបាកខាងសេដ្ឋកិច្ចនៅមូលដ្ឋាន។ ទោះជាមិនទាន់មានភស្តុតាងជាក់ស្តែងច្បាស់លាស់ អំពីទំនាក់ទំនងរវាងការអភិវឌ្ឍ និងចំណាកស្រុកក្តី ក៏ការអភិវឌ្ឍសហគមន៍អាចកាត់បន្ថយចំណាកស្រុកបាន ដោយជួយជំនះលើហេតុផលដែលធ្វើឲ្យជនចំណាកស្រុក ជ្រើសយកវិធីមិនស្របច្បាប់។ វិធានការអាទិភាពដែលអាចយកមកអភិវឌ្ឍសហគមន៍ រួមមានការបង្កើនជំនួយឧបត្ថម្ភផ្នែកកសិកម្ម ការកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ការបង្កើនលទ្ធភាពបានប្រើប្រាស់ធនធានធម្មជាតិ និងការពង្រឹងការផ្គត់ផ្គង់សេវាសាធារណៈ ជាពិសេសការអប់រំ និងការថែទាំសុខភាព។ ជំនួយអភិវឌ្ឍន៍ ត្រូវផ្តោតឲ្យចំសហគមន៍នានាដែលមានអត្រាចំណាកស្រុកខ្ពស់។

*បើកឱកាសឲ្យមានចំណាកស្រុកស្របច្បាប់៖* ដោយមានជម្រើសតិចតួចសម្រាប់ចំណាកស្រុកស្របច្បាប់ ចំណាកស្រុកមិនស្របច្បាប់ ក៏បានក្លាយជាវិធីតែមួយគត់ដែលពលករចំណាកស្រុកកម្ពុជាភាគច្រើន អាចមានលទ្ធភាពធ្វើបាន។ មានការមូលមតិជាអន្តរជាតិ ដូចមានបញ្ជាក់ក្នុងកិច្ចប្រជុំត្រីភាគីនៃ ILO តំបន់អាស៊ី ឆ្នាំ២០០៣ នៅក្រុងបាងកកនោះថា ឱកាសធ្វើចំណាកស្រុកស្របច្បាប់ដោយងាយស្រួល និងមានតម្លាភាពអាចជាចំណែកមួយនៃដំណោះស្រាយដ៏សក្តិសិទ្ធិ ចំពោះបញ្ហាចំណាកស្រុកមិនស្របច្បាប់។ អាទិភាពដ៏សំខាន់បំផុតនៃប្រព័ន្ធស្វែងរកការងារស្របច្បាប់របស់កម្ពុជា គឺត្រូវធ្វើឲ្យសាមញ្ញនូវនីតិវិធីរដ្ឋបាល ពន្លឿនការសម្របសម្រួលសេវា និងកាត់បន្ថយចំណាយលើការរកការងារឲ្យធ្វើ។

*រៀបចំច្បាប់គ្រប់គ្រងទីភ្នាក់ងារឯកជនស្វែងរកការងារឲ្យធ្វើ៖* ការកើតមានព្រឹត្តិការណ៍ធ្ងន់ធ្ងរម្តងហើយម្តងទៀត នៃការមិនអនុវត្តតាម និងអនុវត្តខុសឆ្គង បានបង្ហាញពីតម្រូវការជាបន្ទាន់នូវបទបញ្ញត្តិតឹងរ៉ឹងលើទីភ្នាក់ងារជ្រើសរើសពលករ។ ការជ្រើសរើស និងការដាក់ឲ្យធ្វើការ ត្រូវមានបទបញ្ញត្តិគ្រប់គ្រងតឹងរ៉ឹងតាមរយៈប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ដែលក្នុងនោះមានកំណត់ច្បាស់នូវការទទួលខុសត្រូវរបស់ទីភ្នាក់ងារ លក្ខខណ្ឌជ្រើសរើស និងទោសទណ្ឌ។ បទបញ្ញត្តិល្អ ក៏ត្រូវមានការតាមដានយ៉ាងសកម្មដែរ ដើម្បីធានានូវការអនុវត្តតាមជាអតិបរមា។ ការតាមដានគួរមានទាំងការទទួលបានរបាយការណ៍ពីទីភ្នាក់ងារ ស្តីពីការជ្រើសកន្លែងដាក់ឲ្យធ្វើការ និងស្ថានភាពការងាររបស់ពលករ ការចុះពិនិត្យជាទៀងទាត់ដោយភ្នាក់ងាររដ្ឋាភិបាល ឬអ្នកតំណាង ព្រមទាំងការងារជាច្រើនទៀត។

## ការការពារ និងសុខុមាលភាពរបស់ពលករចំណាកស្រុក

*ពង្រឹងការអប់រំ និងបំផុសចំណាប់អារម្មណ៍៖* ព័ត៌មានកាន់តែប្រសើរ នាំឲ្យមានការការពារកាន់តែប្រសើរ ដូច្នេះគួរជួយពង្រឹងការអប់រំ និងបំផុសចំណាប់អារម្មណ៍របស់ពលករមុនពេលត្រូវចេញដំណើរ។ ព័ត៌មានអាចផ្សព្វផ្សាយបានតាមរយៈការបង្កើតមជ្ឈមណ្ឌលធនធានចំណាកស្រុកថ្នាក់ជាតិ និងថ្នាក់ខេត្ត។ មុខងារសំខាន់ៗរបស់មជ្ឈមណ្ឌល មានជាអាទិ៍ ការចុះបញ្ជីពលករចំណាកស្រុកជាសក្តានុពល និងការផ្តល់ព័ត៌មានតាមរយៈសៀវភៅតូចៗ ផ្ទាំងផ្សព្វផ្សាយ ការពិគ្រោះយោបល់ ទស្សនកិច្ចប្រព័ន្ធផ្សព្វផ្សាយ កិច្ចប្រជុំ និងសិក្ខាសាលា។

*ពង្រីកការផ្តល់សេវាគាំទ្រ៖* ការតែងតាំងអនុព័ន្ធពលកម្មនៅថៃ និងម៉ាឡេស៊ី ដែលមានពលករចំណាកស្រុកកម្ពុជាភាគច្រើនទៅធ្វើការ ជាមធ្យោបាយល្អមួយដើម្បីពង្រឹងសេវាកម្មគាំទ្រ។ ក្នុងមុខងាររបស់អនុព័ន្ធ គួរមានទាំង ការកសាងទំនាក់ទំនងការងាររឹងមាំជាមួយប្រទេសម្ចាស់ផ្ទះ ស្តីពីបញ្ហាពលករ ការតាមដានការអនុវត្តចំពោះពលករចំណាកស្រុក ការផ្តល់ជំនួយផ្នែកច្បាប់ទប់ទល់នឹងការរំលោភកិច្ចសន្យា ការរំលោភបំពាន ការកេងប្រវ័ញ្ច ការជួយមតិអំពីបញ្ហាពាក់ព័ន្ធនឹងកិច្ចសន្យា ឬការងារ និងការធានាឲ្យជនចំណាកស្រុកមិនស្របច្បាប់ ទទួលបានការការពារ និងការជួយសម្រួលនៅពេលធ្វើមាតុភូមិនិវត្តន៍។

## ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ

ចំណាកស្រុក ជាបញ្ហាពហុភាគី ដូច្នេះត្រូវមានការចរចា និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីញ៉ាំងឲ្យចំណាកស្រុកពលករមានរបៀបរៀបរយ និងមានច្បាប់គ្រប់គ្រងត្រឹមត្រូវ (ILO 2010)។ ចំណាកស្រុកមិនស្របច្បាប់ អាចដោះស្រាយបានប្រសើរបំផុតក្នុងក្របខ័ណ្ឌទ្វេភាគី និងតំបន់ ដើម្បីបំពេញបន្ថែមលើគោលនយោបាយជាតិ។

*ការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី៖* កិច្ចសហប្រតិបត្តិការរវាងប្រទេសបញ្ជូន និងប្រទេសទទួល ឃើញមានប្រសិទ្ធភាពល្អក្នុងការដោះស្រាយបញ្ហាចំណាកស្រុកមិនស្របច្បាប់។ អនុស្សរណៈយោគយល់ (MoU) ចុះហត្ថលេខាដោយកម្ពុជា និងថៃក្នុងឆ្នាំ២០០៣ ជាករណីជាក់ស្តែងមួយនៃកិច្ចសហប្រតិបត្តិការដ៏សក្តិសិទ្ធិដើម្បីដោះស្រាយបញ្ហាចំណាកស្រុក។ ឯកសារនេះមានគោលដៅចម្បង ផ្តល់ជាក្របខ័ណ្ឌមួយសម្រាប់ការជ្រើសរើសពលរដ្ឋកម្ពុជាឲ្យទៅធ្វើការនៅថៃ ហើយក៏ព្យាយាមប្រែក្លាយពលករកម្ពុជាមិនស្របច្បាប់ ឲ្យទៅជាពលករស្របច្បាប់ដែរ។ រដ្ឋាភិបាលប្រទេសទាំងពីរបានរួមដៃគ្នាធ្វើការងារនេះ ដោយផ្តល់អត្តសញ្ញាណប័ណ្ណដល់ពលករមិនស្របច្បាប់ ហើយប័ណ្ណនេះអនុញ្ញាតឲ្យពលករ អាចដាក់ពាក្យសុំប័ណ្ណការងាររយៈពេល ២ឆ្នាំបាន។ កម្ពុជាក៏គួរស្នើដល់រដ្ឋាភិបាលម៉ាឡេស៊ី ឲ្យពិចារណាលើការផ្តល់សិទ្ធិស្របច្បាប់ ដល់ពលករកម្ពុជាមិនស្របច្បាប់ទាំងឡាយដែរ។

*ដំណើរបង្កើត ទីផ្សារពលកម្មមហាអនុតំបន់មេគង្គរួមគ្នា៖* ចលនាពលករ ឆ្លងកាត់ព្រំដែនពាសពេញមហាអនុតំបន់មេគង្គ (GMS) មានសន្ទុះខ្លាំង ដោយមានថៃជាគោលដៅទីផ្សារពលកម្មចម្បងមួយ ហើយកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ជាប្រភពនៃពលករគ្មានជំនាញ។ ទោះជាលំហូរពលកម្មក្នុងតំបន់មានទំហំធំ និងសារៈសំខាន់ខាងសេដ្ឋកិច្ចក្តី ប៉ុន្តែបច្ចុប្បន្នមិនទាន់មានបទបញ្ញត្តិសម្រាប់អនុតំបន់ ឬក្របខ័ណ្ឌស្ថាប័ន ដើម្បីសម្របសម្រួលចលនាពលកម្មនៅឡើយទេ។ GMS គួរធ្វើការងារសំដៅបង្កើតទីផ្សារពលកម្មរួមគ្នាមួយ។ គំនិតនេះអាចមានប្រយោជន៍ដល់គ្រប់ប្រទេសចូលរួម។ សម្រាប់ប្រទេសខ្វះពលកម្ម ដូចជា ថៃ ការមានទីផ្សារពលកម្មតំបន់រួមគ្នាមួយ អាចធានានូវការផ្គត់ផ្គង់ពលករយ៉ាងជាប់លាប់ និងអាចទុកចិត្តបាន ហើយកត្តានេះសំខាន់ខ្លាំងណាស់ សម្រាប់ការប្រកួតប្រជែងប្រកបដោយនិរន្តរភាព ក្នុងវិស័យអតិពលកម្មជាច្រើន។ សម្រាប់ប្រទេសសម្បូរពលកម្ម ដូចជា កម្ពុជា ចលនាពលករកាន់តែងាយស្រួលអាចបន្ថយនូវសម្ពាធនៃការអត់ការងារធ្វើ។ ជំហានដំបូង ដើម្បី

សម្រេចគោលដៅនេះ គឺត្រូវដាក់បញ្ចូលចំណាកស្រុកពលករទៅក្នុងរបៀបវារៈអភិវឌ្ឍន៍នៃមហាអនុតំបន់មេគង្គ (GMS) ហើយបន្ទាប់មកបង្កើតវេទិកាអ្នកជំនាញ ដើម្បីសិក្សាពីភាពអាចធ្វើបាន និងផ្តល់អនុសាសន៍ ដល់អ្នកដឹកនាំ។

*សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងចលនាពលកម្មដោយសេរី៖* ចំណាកស្រុកក្នុងអាស៊ាន បានកើនឡើងយ៉ាងគំហុក ប៉ុន្តែមិនទាន់មានក្របខ័ណ្ឌច្បាប់ ឬក្របខ័ណ្ឌស្ថាប័នថ្នាក់តំបន់នៅឡើយទេ។ រហូតដល់ឆ្នាំ២០០៧ ទើបមេដឹកនាំអាស៊ានចុះហត្ថលេខាលើសេចក្តីប្រកាស ស្តីពីការការពារ និងលើកកម្ពស់សិទ្ធិរបស់ពលករចំណាកស្រុក។ មានមនុស្សជាច្រើនគិតថា សេចក្តីប្រកាសនេះ ជាជំហានទីមួយដ៏សំខាន់ដើម្បីឈានទៅដល់ការការពារ និងគោរពសិទ្ធិរបស់ពលករចំណាកស្រុកបានកាន់តែប្រសើរ ប៉ុន្តែការយឺតយ៉ាវក្នុងការតាក់តែងលិខិតុបករណ៍ក្របខ័ណ្ឌ បង្ហាញឲ្យឃើញថា អាស៊ានត្រូវតែបង្កើនល្បឿនអនុវត្តការប្តេជ្ញាចិត្តរបស់ខ្លួនក្រោមសេចក្តីប្រកាសនេះ។ អាស៊ានត្រូវអនុម័តគោលការណ៍ណែនាំ និងបទបញ្ញត្តិចាំបាច់នានា ព្រមទាំងបង្កើតយន្តការស្ថាប័ន ដើម្បីធានាបានការអនុវត្តដោយរលូន និងការតាមដានប្រកបដោយប្រសិទ្ធភាព។ លិខិតុបករណ៍ទាំងនេះ នឹងត្រូវដាក់បញ្ចូលក្នុងលិខិតុបករណ៍ក្របខ័ណ្ឌអាស៊ានដែលមានលក្ខណៈចងភ្ជាប់តាមផ្លូវច្បាប់។

## សេចក្តីសន្និដ្ឋាន

ការវិភាគខាងលើបង្ហាញច្បាស់ថា ចំណាកស្រុកមិនស្របច្បាប់បានផុសឡើងជាបញ្ហាចំបងមួយ ក្នុងការគ្រប់គ្រងចំណាកស្រុកនៅកម្ពុជា។ ការដោះស្រាយចំណាកស្រុកនេះ ជាបញ្ហាអាទិភាពមួយផ្នែកគោលនយោបាយ ដោយត្រូវមានដំណោះស្រាយជារួម និងគ្រប់ជ្រុងជ្រោយ ទាក់ទិននឹងគោលនយោបាយ និងអន្តរាគមន៍ជាក់ស្តែងនៅគ្រប់កម្រិតនៃចំណាកស្រុក ដែលអនុវត្តឡើងដោយអ្នកពាក់ព័ន្ធជាច្រើន។ ជោគជ័យនៃការគ្រប់គ្រងចំណាកស្រុកមិនស្របច្បាប់នៅកម្ពុជា ត្រូវពឹងផ្អែកមិនត្រឹមតែលើសមត្ថភាពរបស់ប្រទេសក្នុងការប្រែក្លាយ "ចំណាកស្រុកដើម្បីរស់រាន" ទៅជា "ចំណាកស្រុកជាជម្រើសមួយ" ប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាស្រ័យទៅលើដំណោះស្រាយរបស់អង្គការកម្រិតតំបន់ ដូចជា GMS និង អាស៊ាន និងរបស់សហគមន៍អន្តរជាតិទៀតផង។

## ឯកសារយោង


Battistella, Graziano (2002), "Unauthorized Migrants as Global Workers in the ASEAN Region", *Southeast Asian Studies* 40(3), pp. 350–371

Brennan, M. Ellen (1984), "Irregular Migration: Policy Responses in Africa and Asia", *International Migration Review* 18(3), pp. 409–425

Chan Sophal (2009), *Costs and Benefits of Cross-Country Labour Migration in the GMS: Cambodia Country Study*, Working Paper No.47 (Phnom Penh: CDRI)

Chiuri, M. Concetta, Giuseppe de Arcangelis & Giovanni Ferri (2005), *Crisis in Countries of Origin and Illegal Immigration into Europe via Italy* (Geneva: Global Commission on International Migration)

Global Commission on International Migration (2005), *Migration in an Interconnected World: New Directions for Action* (Geneva: Global Commission on International Migration)

Hing Vutha, Lun Pide & Phan Dalis (2011), "Labour Migration Situation and Policy Framework in Cambodia", *Annual Development Review 2010–2011*, pp. 83–102

International Council on Social Welfare (2007), *Trafficking and Related Labour Exploitation in the ASEAN Region* (Utrecht: ICSW)

International Labour Organisation (2010), *International Labour Migration: A Rights-based Approach* (Geneva: ILO)

International Organisation for Migration (2003), *Labour Migration in Asia: Trends, Challenges and Policy Responses in Countries of Origin* (Geneva: IOM)

Lee, L. Tang (2005), *Statelessness, Human Rights and Gender: Irregular Migrant Workers from Burma in Thailand* (Leiden: Koninklijke Brill NV)

LeVoy, Michele & Eve Geddie (2010), "Irregular Migration: Challenges, Limits and Remedies", *Refugee Survey Quarterly* 28(4), pp. 87–113

Marshall, Phil (2001), *Globalization, Migration and Trafficking: Some Thoughts from the South-East Asian Region,* (Kuala Lumpur: UN Inter-Agency Project on Trafficking in Women and Children in the Mekong Subregion)

MLVT (2010), *Policy on Labour Migration for Cambodia* (Phnom Penh: Ministry of Labour and Vocational Training)

Naro, Neth (2009), *Human Trafficking in Cambodia: Reintegration of the Cambodian Illegal Migrants from Vietnam and Thailand,* Working Paper No 181 (Singapore: S. Rajaratnam School of International Studies)

Paitoonpong, Srawooth and Chothiga Sakuruji (forthcoming), *Managing International Labour Migration in ASEAN* (Bangkok: Thailand Development Research Institute)

Shah, Nasra (2009), *The Management of Irregular Migration and Its Consequences for Development: Gulf Cooperation Council,* Working Paper No.19 (Bangkok: International Labour Organisation)

Stoyanova, Mariya (2008), *Challenges of Irregular Migration* (Geneva: Friedrich Ebert Stiftung)

UN General Assembly, "Resolution 3449: Measure to Ensure the Human Rights and Dignity of All Migrant Workers", http://www.un.org/documents/ga/res/30/ares30.htm (accessed 27 August 2010)

UNIAP (2010), *Human Trafficking Sentinel Surveillance: Poipet, Cambodia 2009-2010* (Bangkok: United Nations Inter-Agency Project on Human Trafficking)